ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ២២/១១-បានចាម៉ាត ខនស្ត្រាក់សិន

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: ឈីវ ភិរម្យ

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: អន ណន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន**

អាសយដ្ឋាន : ភូមិព្រៃគគី ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត

ទូរស័ព្ទ : ០៨៥ ២៤២ ៩៩០ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក អ៊ុយ ពិសិដ្ឋ តំណាងក្រុមហ៊ុន បានចាម៉ាត

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : - **សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា**

- **សហជីពកម្មករសំណង់ប្រចាំក្រុមហ៊ុន កំពត ស៊ីមេន ខុនិលធូឌី**

អាសយដ្ឋាន : ភូមិព្រៃគគី ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត

ទូរស័ព្ទ : ០១២ ៧៩២ ៦១៧ ទូរសារ : គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក សុខ សុវណ្ណដេត | ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា |
| ២- លោក វ៉ាន់ ថុល | អនុប្រធានទី១ សហព័ន្ធសហជីព |
| ៣- លោក សុខ គីន | អនុប្រធានទី២ សហព័ន្ធសហជីព |
| ៤- លោក ឈុន ពៅ | ប្រធានសហជីពកម្មករសំណង់ប្រចាំក្រុមហ៊ុនកំពតស៊ីមេន |
| ៥- លោក ទេព ម៉ៅ | ហិរញ្ញិកសហជីព |
| ៦- លោក ស៊ីវ សុធា | អ្នកអម |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

<u>ចំណុចបណ្តឹងទាមទាររួមមាន</u> :

១- ឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញតាមជំនាញដដែល ។

២- ឱ្យក្រុមហ៊ុនគិតប្រាក់រំលឹកចាប់ពីថ្ងៃ ដែលក្រុមបានបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ។

៣- ក្រុមហ៊ុនត្រូវបញ្ឈប់ការរើសអើងសហជីព និងគំរាមកំហែងកម្មករ ។

៤- ក្រុមហ៊ុនត្រូវអនុវត្តការឈប់សម្រាកថ្ងៃឈប់សម្រាកបុណ្យជាតិដោយមានប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារ ។

៥- ក្រុមហ៊ុនត្រូវអនុវត្តការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារ ។

៦- ក្រុមហ៊ុនត្រូវអនុវត្តការងារវេនយប់ដោយគិតប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារ ។

<u>ចំណុចដែលមិនព្រមព្រៀងមាន</u> :

១- កម្មករ ០២ នាក់ របស់ក្រុមហ៊ុន Banjamat និង ០១ នាក់ របស់ក្រុមហ៊ុន Kron 2010 មិនឱ្យចូលធ្វើការវិញ ។

២- មិនគិតប្រាក់រំលឹកទេ ។

៣- ក្រុមហ៊ុនមិនត្រូវរើសអើងសហជីព និងគំរាមកំហែងកម្មករ ។

៤- ក្រុមហ៊ុនត្រូវអនុវត្តការឈប់សម្រាកថ្ងៃឈប់សម្រាកបុណ្យជាតិដោយមានប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារ ។

៥- ក្រុមហ៊ុនត្រូវអនុវត្តការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារ ។

៦- ក្រុមហ៊ុនត្រូវអនុវត្តការងារវេនយប់ដោយគិតប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០២៤ មកបវ.កព ០១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ : ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:០០ នាទី រសៀល)។

បញ្ហានៃនីតិវិធី :

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា លេខ ០០២/១០ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងផ្សះផ្សា នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៦ ចំណុច លើការទាមទារចំនួន ០៦ ចំណុច។ ចំណុចវិវាទ ដែលមិនសះជានឹងគ្នាចំនួន ០៦ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ០២៤ មកបវ.កព០១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ១៤:០០ នាទី រសៀល។

THE ARBITRATION COUNCIL

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៦ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន៤ចំណុចគឺ ចំណុចវិវាទទី៣ ចំណុចវិវាទទី៤ ចំណុចវិវាទទី៥ និងចំណុចវិវាទទី៦ ។ ចំណែកឯចំណុចមិនសះជាមាននៅសល់ចំនួន០២ចំណុច គឺ ចំណុចវិវាទទី១ និងចំណុចវិវាទទី២ ។ ដោយសារចំណុចវិវាទទី១ និងចំណុចវិវាទទី២ ពាក់ព័ន្ធគ្នា ភាគីកម្មករនិយោជិតយល់ព្រមដាក់ចំណុចវិវាទទាំងពីរនេះបញ្ចូលគ្នាតែមួយ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយចំណុចវិវាទទី១ និងទី២ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន បានចាម៉ាត ជូនលោក អ៊ុយ ពិសិដ្ឋ ។

២- ប័ណ្ណប៉ាតង់ ឆ្នាំ២០១០ របស់ក្រុមហ៊ុន បានចាម៉ាត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ ។

៣- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ក្រុមហ៊ុន បានចាម៉ាត ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧ ។

៤- តារាងវាយតម្លៃសមត្ថភាពកម្មករក្រុមហ៊ុន ខីន និង ខូមីល ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១០ ។

៥- លិខិតរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា លេខ ០០៣៩/១០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១០ គោរពជូនលោកប្រធានគ្រប់គ្រងការដ្ឋានកំពត់ស៊ីមេន ស្តីពីការសុំជួបពិភាក្សាបញ្ហាមួយចំនួន ។

៦- លិខិតសុំជួបចរចារពីបញ្ហាផ្លាស់ប្តូរពួកយើងខ្ញុំពីឈុតក្នុងមកឈុតក្រៅរបស់លោក ឈុន ពៅ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១០ ។

៧- ពាក្យបណ្តឹងសុំរក្សាការពាររបស់តំណាងក្រុមហ៊ុ បានចាម៉ាត គោរពជូនលោកប្រធានសាលាដំបូងខេត្តកំពត ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ។

៨- ពាក្យបណ្តឹងរបស់លោក អ៊ុយ ពិសិដ្ឋ គោរពចូលមកលោកឧត្តមសេនីយ៍ស្នងការនគរបាលខេត្តកំពត ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ ។

៩- ដីការរក្សាការពាររបស់សាលាដំបូងខេត្តកំពតលេខ ៣៧៦ រវ/០១០ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ។

THE ARBITRATION COUNCIL

១០- លិខិតបញ្ឈប់ការងារកម្មករឈ្មោះ ឈុន ពៅ និងឈ្មោះ ទេព ម៉ៅ របស់ក្រុមហ៊ុន បានចាម៉ាត លេខ B 002 ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ។

១១- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន បានចាម៉ាត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ។

១២- ចំណុចបំភ្លឺលើគំរោងផែនការផ្លាស់ប្តូរកម្មករពីឈុតក្នុងមកឈុតក្រៅ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១ ។

១៣- លិខិតជំទាស់លើសំណុំឯកសារសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១- សារណាសង្ខេបវិវាទការងារលើសំណុំរឿងលេខ ២២/១១ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ ។

២- លក្ខន្តិកៈសហជីពកម្មករសំណង់ប្រចាំក្រុមហ៊ុនកំពត ស៊ីមេន ខូអិលធីឌី ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣- លិខិតរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា លេខ ០០៣៧/១០ លេខ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូនលោក អគ្គនាយកក្រុមហ៊ុន កំពត ស៊ីមេន ស្តីពីការជូនដំណឹងរៀបចំបោះឆ្នោតបង្កើតសហជីព ។

៤- លិខិតសុំចុះបញ្ជិកាសហជីពកម្មករសំណង់ប្រចាំក្រុមហ៊ុន កំពត ស៊ីមេន ខូអិលធីឌី លេខ ០០១/១០ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៥- បង្កាន់ដៃសុំចុះបញ្ជិកាសហជីព ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦- លិខិតបញ្ឈប់ការងារកម្មករឈ្មោះ ឈុន ពៅ និងឈ្មោះ ទេព ម៉ៅ របស់ក្រុមហ៊ុន បានចាម៉ាត ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ ។

៧- លិខិតរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា លេខ ០០៣៧/១០ លេខ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំការពារបេក្ខជនឈរឈ្មោះបោះឆ្នោតជាថ្នាក់ដឹកនាំសហជីព ។

៨- លិខិតរបស់សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា លេខ ០០៤២/១០ លេខ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំចុះបញ្ជិកាសហជីព ។

THE ARBITRATION COUNCIL

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន បានចាម៉ាត និងក្រុមហ៊ុន Kron លេខ ០២៤ មកបវ.កព ០១១ ចុះថ្ងៃទី២៤ ខែកភា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន បានចាម៉ាត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៤០ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៤១ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

- ភាគីនិយោជកលើកឡើងថា ក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន ទទួលម៉ៅការបន្តពីក្រុមហ៊ុន ខេ-ស៊ីមែន ក្នុងផ្នែកសំណង់ស៊ីវិល និងមើលថែទាំម៉ាស៊ីន។ ក្រុមហ៊ុន បាចាម៉ាត ខនស្រ្តាក់សិន ទទួលម៉ៅការតាំងពីឆ្នាំ ២០០៦ មកដល់ឆ្នាំ២០១១។
- សហជីពសំណង់ប្រចាំក្រុមហ៊ុន ខេ ស៊ីមែន ដែលជាដើមបណ្តឹងក្នុងរឿងនេះ មិនទាន់ទទួលបានបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឡើយទេ។

ចំណុចវិវាទទី១ និងទី២: ភាគីកម្មករនិយោជិតទាមទារ ឱ្យក្រុមហ៊ុនទទួលកម្មករនិយោជិត ឈ្មោះ ឈុន ពៅ និងឈ្មោះ ទេព ម៉ៅ ចូលធ្វើការនៅកន្លែងដើមវិញ និងសងប្រាក់រំលឹកតាំងពីពេលបញ្ឈប់ពីការងាររហូតដល់ពេលចូលធ្វើការវិញ

<u>ករណីកម្មករនិយោជិត ឈ្មោះ ឈុន ពៅ :</u>

- លោក ឈុន ពៅ បានចូលធ្វើការនៅក្នុងក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០១០ ក្រោមកិច្ចសន្យាការងារផ្ទាល់មាត់ ដោយគ្មានថិរវេលាកំណត់ នៅផ្នែកពិនិត្យម៉ាស៊ីន (ហៅថា

THE ARBITRATION COUNCIL

ឈុតក្នុង) ។ លោកទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃចំនួន ២១.១០០ រៀល ក្នុងមួយថ្ងៃ។ ក្រោយធ្វើការបាន ៦ខែ ក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ២,៥ ភាគរយ ។ ហេតុនេះ លោកទទួលបានប្រាក់ឈ្នួល ២១.៥០០ រៀល ក្នុងមួយថ្ងៃ។

- លោក ឈុន ពៅ ធ្វើការ ៨ ម៉ោង ក្នុងមួយថ្ងៃ និងធ្វើការ៥ថ្ងៃ ឈប់សម្រាកមួយថ្ងៃ ពោលគឺលោកឈប់សម្រាកប្រចាំសប្តាហ៍មួយថ្ងៃរៀងរាល់៥ថ្ងៃម្តង មិនថា ចំលើថ្ងៃណាមួយទេ។ ម៉ោងការងាររបស់លោក គឺពីម៉ោង ២ រសៀល ដល់ ម៉ោង ១០ យប់ ។

<u>ករណីកម្មករនិយោជិតឈ្មោះ ទេព ម៉ៅ :</u>

- លោក ទេព ម៉ៅ បានចូលធ្វើការនៅក្នុងក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០១០ ក្រោមកិច្ចសន្យាការងារផ្ទាល់មាត់ ដោយគ្មានថិរវេលាកំណត់ នៅផ្នែកពិនិត្យម៉ាស៊ីន (ហៅថា ឈុតក្នុង) ។ លោកទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ គឺ ១៥.៨០០ រៀល ក្នុងមួយថ្ងៃ។ ក្រោយធ្វើការបាន ៦ ខែ ក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ២,៥ ភាគរយឱ្យ ហេតុនេះលោកទទួលបានប្រាក់ឈ្នួល ១៦.៣០០ រៀល ក្នុងមួយថ្ងៃ។
- លោក ទេព ម៉ៅ ធ្វើការ ៨ ម៉ោង ក្នុងមួយថ្ងៃ និងធ្វើការ៥ថ្ងៃ ឈប់សម្រាកមួយថ្ងៃ ពោលគឺលោកឈប់សម្រាកប្រចាំសប្តាហ៍មួយថ្ងៃរៀងរាល់៥ថ្ងៃម្តង មិនថា ចំលើថ្ងៃណាមួយទេ។ ម៉ោងការងាររបស់លោក គឺពីម៉ោង ២ រសៀល ដល់ ម៉ោង ១០ យប់ ។
- លោក ទេព ម៉ៅ ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ជាមួយគ្នានឹងលោក ឈុន ពៅ ដែរ។

មូលហេតុនៃការបញ្ឈប់ការងារលោក ឈុន ពៅ និង លោក ទេព ម៉ៅ

- ក្រុមហ៊ុនបានបញ្ជាក់ពីមូលហេតុនៃការបញ្ឈប់រូបលោក ឈុន ពៅ និងលោក ទេព ម៉ៅ ថា ដោយសារតែលោកទាំងពីរនាក់នេះ មិនស្តាប់តាមការណែនាំរបស់ក្រុមហ៊ុន។ ការបញ្ឈប់នេះ ក្រុមហ៊ុនអះអាងថា ដោយផ្អែកលើកកំហុសឆ្គងរបស់កម្មករនិយោជិតទាំងពីរនាក់ចំនួនពីរលើក គឺ:
    - លើកទី១ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០ កម្មករនិយោជិតទាំងពីរអ្នកនេះ បានសរសេរលិខិតជាលាយលក្ខណ៍អក្សរ ក្នុងអត្ថន័យសុំជួបចរចាពីបញ្ហាផ្លាស់ប្តូរពួកគាត់ពីការងារនៅក្នុងផ្នែក ឈុតក្នុង ដែលជាការងារមានសម្រាប់រយៈពេលយូរ ទៅធ្វើការនៅផ្នែកឈុតក្រៅ ដែលជាការងារសម្រាប់រយៈពេលខ្លីៗ។
    - លើកទី២ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១៥:៤០ នាទី ដល់ម៉ោង ២០:១០ នាទី

មានការតវ៉ារបស់កម្មករនិយោជិតចំនួន២០នាក់របស់ក្រុមហ៊ុនចំនួន ២ ដែលធ្វើការនៅក្នុងការដ្ឋានក្រុមហ៊ុន ខេ ស៊ីមែន (កំពត ស៊ីមែន) បានចេញពីម៉ោងការងាររបស់ខ្លួនមកធ្វើការតវ៉ាសួរពីបញ្ហាប្តូរទីតាំងការងាររបស់លោក ឈុន ពៅ និងលោក ទេព ម៉ៅ ហើយដែលក្នុងចំណោមពួកគេនោះ មានកម្មករនិយោជិតរបស់ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ចំនួន ៨ នាក់បានចូលរួមដែរ។

- កម្មករនិយោជិតទទួលស្គាល់ថា ខ្លួនពិតជាបានទៅធ្វើការតវ៉ាពីរឿងការផ្លាស់ប្តូរនេះនៅក្នុងម៉ោងការងារមែន មូលហេតុដោយសារលោក សម្បត្តិ ដែលជាប្រធានផ្នែករបស់លោក ឈុន ពៅ បានប្រាប់គាត់ថាលោកនឹងត្រូវបានក្រុមហ៊ុនផ្លាស់ប្តូរការងារពីផ្នែកឈុតក្នុង ទៅផ្នែកឈុតក្រៅ។
- កម្មករនិយោជិត និងក្រុមហ៊ុនឯកភាពថា ការបញ្ឈប់នេះ គឺមិនមានការជូនដំណឹងមុនឡើយ ហើយលោក ឈុន ពៅ និងលោក ទេព ម៉ៅ ក៏មិនទាន់បានទទួលប្រាក់ឈ្នួលចុងក្រោយរបស់ពួកគាត់ដែរ។
- កម្មករនិយោជិត និងនិយោជកឯកភាពថា លោក ឈុន ពៅ និងលោក ទេព ម៉ៅ គឺជាកម្មករនិយោជិតរបស់ក្រុមហ៊ុន បានចាម៉ាត។
- លោក ឈុន ពៅ និងលោក ទេព ម៉ៅ បានបញ្ជាក់ថា លោកជាថ្នាក់ដឹកនាំរបស់សហជីពសំណង់ប្រចាំក្រុមហ៊ុន កំពត ស៊ីមែន។

<u>ករណីសហជីព :</u>

- ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតបានចូលរួមបង្កើតសហជីព ដែលដាក់ឈ្មោះថា សហជីពសំណង់ប្រចាំក្រុមហ៊ុន ខេ ស៊ីមែន។ កម្មករនិយោជិតបញ្ជាក់ថា ការបង្កើតសហជីពនេះ គឺដោយយល់ឃើញថា ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន និងក្រុមហ៊ុនម៉ៅការផ្សេងៗទៀត គឺជាផ្នែកនៃក្រុមហ៊ុន ខេ ស៊ីមែន។ ហេតុនេះ ទើបការបោះឆ្នោត និងនីតិវិធីផ្សេងៗត្រូវបានកម្មករនិយោជិតជូនដំណឹងតែទៅក្រុមហ៊ុន ខេ ស៊ីមែន ប៉ុណ្ណោះ។ ជាក់ស្តែងដូចជា :
  - ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ សហជីពជូនដំណឹងទៅក្រុមហ៊ុន ខេ ស៊ីមែន ស្តីពីការរៀបចំបោះឆ្នោតថ្នាក់ដឹកនាំសហជីព និងឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត តាមរយៈលិខិតចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១០។
  - ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១០ សហជីពបានរៀបចំការបោះឆ្នោតថ្នាក់ដឹកនាំសហជីព ដែលមានកម្មករនិយោជិតចំនួន ១១៩ នាក់ ពីក្រុមហ៊ុនម៉ៅការផ្សេងៗ រួមទាំងកម្មករនិយោជិតរបស់ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន នៅក្នុងការដ្ឋានក្រុមហ៊ុន ខេ ស៊ីមែន បានចូលរួមបោះឆ្នោត។

THE ARBITRATION COUNCIL

- កម្មករ ដែលជាប់ជាថ្នាក់ដឹកនាំសហជីព មានឈ្មោះ (១) ឈុន ពៅ (២) ទេព ម៉ៅ (៣) ម៉ៅ ញ៉ (៤) ពៅ ស្រីមុំ និង (៥) ផុន គ្រប។
- ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ សហជីពបានដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប៉ុន្តែមិនទាន់ទទួលបានបញ្ជិកានៅឡើយ ដោយសារតែមានការតវ៉ាពីក្រុមហ៊ុន ខេ ស៊ីមែន ដែលបដិសេធមិនទទួលស្គាល់ថ្នាក់ដឹកនាំសហជីព ព្រោះកម្មករទាំងនេះមិនមែនជាកម្មករនិយោជិតរបស់ក្រុមហ៊ុន ខេ ស៊ីមែន នោះទេ។

- ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ទទួលស្គាល់ថា ក្រុមហ៊ុនបានដឹងថា មានការបង្កើតសហជីពនៅក្នុងការដ្ឋានក្រុមហ៊ុន ខេ ស៊ីមែន ហើយសហជីពនេះ ជាសហជីពរបស់ក្រុមហ៊ុន ខេ ស៊ីមែន មិនមែនជាសហជីពរបស់ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ទេ។
- ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលកម្មករឈ្មោះ ឈុន ពៅ និង ទេព ម៉ៅ ចូលធ្វើការនៅកន្លែងដើមវិញ និងសងប្រាក់រំលឹកតាំងពីពេលបញ្ឈប់ពីការងារ រហូតដល់ពេលចូលធ្វើការវិញ ដោយយល់ឃើញថា ការបញ្ឈប់ពួកគេពីការងារមិនត្រឹមត្រូវ។ ចំណែកនិយោជកមិនឯកភាពទេ ព្រោះកម្មករនិយោជិតទាំងពីរនាក់នេះមិនស្តាប់ការណែនាំ។
- ក្រុមហ៊ុនមិនបានផ្តល់បទបញ្ជាផ្ទៃក្នុងរបស់ខ្លួនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីពិចារណាលើករណីនេះឡើយ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

ចំណុចវិវាទទី១ និងទី២: ភាគីកម្មករនិយោជិតទាមទារ ឱ្យក្រុមហ៊ុនទទួលកម្មករនិយោជិតឈ្មោះ ឈុន ពៅ និង ទេព ម៉ៅ ចូលធ្វើការនៅកន្លែងដើមវិញ និងសងប្រាក់រំលឹកតាំងពីពេលបញ្ឈប់ពីការងារ រហូតដល់ពេលចូលធ្វើការវិញ

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលកម្មករនិយោជិតឈ្មោះ ឈុន ពៅ និង ទេព ម៉ៅ ចូលធ្វើការនៅកន្លែងដើមវិញ និងសងប្រាក់រំលឹកតាំងពីពេលបញ្ឈប់ពីការងារ រហូតដល់ពេលចូលធ្វើការវិញ ដោយយល់ឃើញថា ការបញ្ឈប់ពួកគេពីការងារនេះ មិនត្រឹមត្រូវ។ ចំណែកនិយោជកមិនឯកភាពទេ ព្រោះកម្មករនិយោជិតទាំងពីរនាក់នេះមិនស្តាប់ការណែនាំ។ មុននឹងពិចារណាលើករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោមៈ

- តើវិវាទនេះជាវិវាទរួម ឬវិវាទបុគ្គល?
- តើលោក ឈុន ពៅ និង ទេព ម៉ៅ ជាប្រភេទកម្មករនិយោជិតដែលទទួលការការពារពិសេសដែរ ឬទេ?
- តើការបញ្ឈប់ការងារលោក ឈុន ពៅ និង ទេព ម៉ៅ ត្រឹមត្រូវតាមច្បាប់ដែរ ឬទេ?

១.តើវិវាទនេះជាវិវាទរួម ឬវិវាទបុគ្គល?

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា ជាគោលការណ៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែដោះស្រាយតាមរបាយការណ៍កំណត់ហេតុមិនសះជា ដែលបញ្ជូនមកដោយក្រសួងការងារ ប្រសិនបើគ្មានការស្នើសុំរបស់ភាគី ឬការបដិសេធ និងលើកហេតុផលបញ្ជាក់របស់ភាគីថា វិវាទដែលក្រសួងការងារបញ្ជូនមកនោះ មិនមែនជាវិវាទរួមទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលចំណុចវិវាទទី៤, លេខ ០២/០៤- សណ្ឋាគារ កាំបូឌីយ៉ាណា , លេខ ៤១/០៤-មីកាសា, លេខ ០៧/០៥-កូកាកូឡា និងលេខ ៦១/០៥ - ស៊ុនទ្រី*) ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របលើការបកស្រាយខាងលើដែរ ហើយក្នុងករណីនេះភាគីនិយោជកមិនបានជំទាស់ថា វិវាទនេះជាវិវាទរួម ឬមិនមែននោះទេ។ ហេតុនេះហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើករណីនេះ ។

២. តើលោក ឈុន ពៅ និង ទេព ម៉ៅ ជាប្រភេទកម្មករនិយោជិត ដែលទទួលការការពារពិសេសដែរ ឬទេ?

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើបានលុះត្រាណាតែមានការយល់ព្រមពីអធិការការ ងារ...."*។

កថាខណ្ឌទី៣ ប្រការ៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា" *កម្មករនិយោជិតទាំងអស់ ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារ ដូចប្រតិភូបុគ្គលិកដែរ។ ការការពារនេះមានរយៈពេល ៤៥ ថ្ងៃមុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត។ សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ ដែលទុកជាបានការ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះនៅរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព*"។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី៣ ប្រការ៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បេក្ខជនឈរឈ្មោះបោះឆ្នោតជាថ្នាក់ដឹកនាំសហជីពទទួលបានការការពារពីការបញ្ឈប់ពីការងារ។

នៅក្នុងសេចក្តីបង្គាប់មុន ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*កម្មករនិយោជិតអាចទទួលបានការការពារពិសេស ដរាបណា (១)កម្មករនិយោជិតជាប្រភេទកម្មករ ដែលទទួលបានការការពារពិសេស (២)ការបញ្ឈប់ត្រូវធ្វើឡើង ក្នុងអំឡុងពេលដែលត្រូវទទួលបានការការពារពិសេស និង(៣)សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាព កម្មករដែលត្រូវទទួលការការពារតាមមធ្យោបាយទាំងអស់ ដែលទុកជាបានការ*"។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ១២២/០៥-វ៉ាយ វី ភី ហេតុផលចំណុចវិវាទទី៣* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងសំណុំរឿងមុនៗដែរ។ យោងតាមអង្គហេតុលោក ឈុន ពៅ និងលោក ទេព ម៉ៅ ជាបេក្ខជនឈរឈ្មោះ និងជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពរបស់ក្រុមហ៊ុន ខេ ស៊ីមែន មិនមែនជាសហជីពរបស់ក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ទេ។ ហើយបន្ថែមពីលើនេះ លោក ឈុន ពៅ និងលោក ទេព ម៉ៅ មិនមែនជាកម្មករនិយោជិត ដែលទទួលបានការការពារតាមមាត្រា ២៩៣ និងប្រការ ៣ នៃប្រកាស ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ដូចការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ឈុន ពៅ និង ទេព ម៉ៅ មិនទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារទេ។

៣. តើការបញ្ឈប់ការងារលោក ឈុន ពៅ និង ទេព ម៉ៅ ត្រឹមត្រូវតាមច្បាប់ ឬទេ?

តាមអង្គហេតុខាងលើ កម្មករនិយោជិត ឈុន ពៅ និង ទេព ម៉ៅ មានកិច្ចសន្យាមានថិរវេលាមិនកំណត់។

មាត្រា ៧៤ នៃច្បាប់ស្តីពីការងារចែងថា" *កិច្ចសន្យាការងារ ដែលមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន។ ការរំលាយកិច្ចសន្យានេះ ត្រូវអនុវត្តទៅតាមរបៀបឱ្យដំណឹងមុនជាលាយលក្ខណ៍អក្សរ ដែលភាគីមានបំណងចង់រំលាយកិច្ចសន្យាត្រូវឱ្យទៅភាគីម្ខាងទៀត។*

*ក៏ប៉ុន្តែគ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបាន ដោយគ្មានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាសរបស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុនឡើយ*"។

ផ្អែកលើខ្លឹមសារនៃមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមានសិទ្ធិបញ្ឈប់កម្មករនិយោជិតដោយឆន្ទៈខ្លួនឯងបានដោយ*ផ្តល់ដំណឹងដល់កម្មករនិយោជិត* ដោយបញ្ជាក់ពី*ហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាសរបស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុន*។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥១/០៨ - អេ អេស ឌី ហេតុផលចំណុចវិវាទទី៣)។

នៅក្នុងសំណុំរឿងនេះ ក្រុមហ៊ុនបានបញ្ឈប់កម្មករនិយោជិតទាំងពីរនាក់ ដោយមិនបានជូនដំណឹងជាមុន ប៉ុន្តែដោយហេតុផលថា ពួកគាត់មិនស្តាប់តាមការណែនាំរបស់ក្រុមហ៊ុន ហើយនៅតែធ្វើការតវ៉ាទាក់ទងនឹងការប្តូរកន្លែងការងារ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការបញ្ឈប់លោក ឈុន ពៅ និងលោក ទេព ម៉ៅ ដោយ ផ្អែកលើហេតុផលនៃការធ្វើការតវ៉ានេះ ជាហេតុផលសម្ប *ទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុន* ឬទេ?

មាត្រា ៣១៨ នៃច្បាប់ស្តីពីការងារចែងថា "*កូដកម្ម គឺជាការឈប់ធ្វើការងារដោយកម្មករនិយោជិតមួយ*

THE ARBITRATION COUNCIL

*ក្រុម ដែលមានការព្រមព្រៀងគ្នា ហើយបានធ្វើឡើងនៅក្នុងសហគ្រាសមួយ ឬគ្រឹះស្ថានមួយ ក្នុងគោលបំណង ដើម្បីទទួលបាននូវដំណោះស្រាយដ៏យុត្តិធម៌ ចំពោះការទាមទាររបស់កម្មករនិយោជិតពីនិយោជក ហើយក៏ជាល័ក្ខខ័ណ្ឌ ដើម្បីចូលធ្វើការវិញ "*។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ បានធ្វើការបកស្រាយមាត្រា ៣១៨ ដែលអាចឱ្យធាតុផ្សំនៃកូដកម្មចំនួនបីជាសារវ័ន្ត គឺ (១) មានក្រុមកម្មករមួយក្រុម (២) ការឈប់ធ្វើការ (៣) ការឈប់នេះ គឺមានគោលបំណងនៃការទាមទារ ដើម្បីទទួលបានដំណោះស្រាយមួយ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣៦/០៦ - ម៉ុងដូតិច ហេតុផលចំណុចវិវាទទី ៦ និងលេខ ១២៥/០៩-វីនខេម ឧបភើរសេិន ហេតុផលចំណុចវិវាទទី១)* ។

យោងតាមអង្គហេតុ លោក ឈុន ពៅ និងលោក ទេព ម៉ៅ រួមទាំងកម្មករនិយោជិតផ្សេងទៀត ចំនួនសរុប ទាំងអស់ ២០ នាក់ បានធ្វើការតវ៉ា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១៩:៤០ នាទី ដល់ម៉ោង ២០:១០ ទាក់ទងនឹងការទាមទារពីការប្តូរកន្លែងការងាររបស់លោក ឈុន ពៅ និងលោក ទេព ម៉ៅ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការតវ៉ានេះ គឺជាកូដកម្ម ព្រោះធ្វើឡើងដោយកម្មករនិយោជិតមួយក្រុម ដោយឈប់ធ្វើការងារក្នុងម៉ោងធ្វើការ ហើយទាមទារឱ្យនិយោជកដោះស្រាយបញ្ហាក់បញ្ហាប្តូរកន្លែងការងារ ។

យោងតាមមាត្រា ៣៣២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារបានចែងថា *"កម្មករនិយោជិតត្រូវបានទទួលការងាររបស់ខ្លួនវិញនៅពេលចប់កូដកម្ម"* ។

មាត្រា ៣៣៣ នៃច្បាប់ស្តីពីការងារបានចែងថា *"ត្រូវហាមឃាត់មិនឱ្យនិយោជកដាក់ទណ្ឌកម្មអ្វីមួយទៅលើកម្មករនិយោជិត ដោយយកលេសនៃការចូលរួមធ្វើកូដកម្មរបស់សាមីជន។ រាល់ការដាក់ទណ្ឌកម្មរបៀបនេះ ត្រូវចាត់ទុកជាមោឃៈ ហើយនិយោជកត្រូវទទួលពិន័យជាប្រាក់ទៅតាមការកំណត់នៃជំពូកទី១៦ មាត្រា ៣៦៩ "* ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ការបញ្ឈប់កម្មករនិយោជិតពីការងារដោយផ្អែកលើមូលហេតុនៃការចូលរួមធ្វើកូដកម្មរបស់កម្មករនិយោជិត គឺ ខុសច្បាប់។ ( *សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០១/០៦-ហ្គោលតិច ហេង សេង ហេតុផលចំណុចវិវាទទី៧, លេខ ១២៥/០៩-វីនខេម ឧបភើរសេិន ហេតុផលចំណុចវិវាទទី១, លេខ ១៤៨/០៩-ហ្គូគីស ហ្គូតវ៉េ ហេតុផលចំណុចវិវាទទី១* ) ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។ ដូច្នេះ ការបញ្ឈប់កម្មករនិយោជិតខាងលើដោយផ្អែកលើ ហេតុផល ដែលពួកគាត់តវ៉ាពោលគឺធ្វើកូដកម្ម គឺផ្ទុយទៅនឹងមាត្រា ៣៣២ និង ៣៣៣ នៃច្បាប់ស្តីពីការងារ និងផ្ទុយពីយុត្តិសាស្ត្រ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនៗផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា ការបញ្ឈប់របស់និយោជក គឺមិនមានហេតុផលសមរម្យ *ទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុន* ឡើយ ។

THE ARBITRATION COUNCIL

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបង្គាប់ឱ្យក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ទទួលយកលោក ឈុន ពៅ និងលោក ទេព ម៉ៅ ចូលធ្វើការវិញ និងសងប្រាក់រំលឹកតាំងពីពេលបញ្ឈប់ពីការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

ចំណុចវិវាទទី ១ និង២ : បង្គាប់ឱ្យក្រុមហ៊ុន បានចាម៉ាត ខនស្ត្រាក់សិន ទទួលយកលោក ឈុន ពៅ និងលោក ទេព ម៉ៅ ចូលធ្វើការវិញ និងសងប្រាក់រំលឹកតាំងពីពេលបញ្ឈប់ពីការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។

ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម ធិរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល THE ARBITRATION COUNCIL